មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
National Maternal and Child Health Center

# ទិវាសល្យសាស្ត្រ សម្ភព និងរោគស្ត្រី លើកទី៤

ប្រធានបទ៖ «រួមគ្នាបង្កើនគុណភាពសេវាព្យាបាល ថែទាំ និងសង្គ្រោះមាតា និងទារក »

## វឌ្ឍនភាពនៃការប្រើប្រាស់សំណុំឯកសារថែទាំសម្រាប់ឆ្មបក្នុង មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក



CMC-LP-003696

ថ្ងៃទី២-៣ ខែកញ្ញា ឆ្នាំ២០២៦
មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

Presented by **KHIM CHHORLIKA**
Positions : **Head of Nursing**

# ការប្រើប្រាស់ សំណុំឯកសារថែទាំសម្រាប់ឆ្មបក្នុង NMCHC

## មាតិកា

1. សេចក្តីផ្តើម
2. គោលបំណង
3. លទ្ធផលនៃការ ប្រើប្រាស់ សំណុំឯកសារថែទាំសម្រាប់ឆ្មបក្នុង NMCHC
4. ការស្ទង់មតិបុគ្គលិកឆ្មបក្នុងការប្រើប្រាស់ សំណុំឯកសារថែទាំសម្រាប់ឆ្មប
5. សេចក្តីសន្និដ្ឋាន
6. អនុសាសន៍

# ១.សេចក្តីផ្តើម

ក្រសួងសុខាភិបាលដាក់ឱ្យប្រើប្រាស់នៅសំណុំឯកសារថែទាំសម្រាប់ឆ្មបដើម្បីពង្រឹងគុណភាពសេវាសុខាភិបាល និងបង្ហាញពីសារៈសំខាន់ជាយុទ្ធសាស្ត្រនៃសំណុំឯកសារនេះក្នុងប្រព័ន្ធសុខាភិបាលជាតិ។ការកំណត់រចនាសម្ព័ន្ធឯកសារនេះមានគោលបំណងកាត់បន្ថយហានិភ័យនៃការភាន់ច្រឡំទិន្នន័យអ្នកជំងឺ និងបង្កើនល្បឿននៃការអន្តរាគមន៍ និងផ្តល់សេវាថែទាំ។ការប្រើប្រាស់និមិត្តសញ្ញាពណ៌នៅលើសំណុំឯកសារដើម្បីងាយស្រួលក្នុងការសម្គាល់ដោយភ្នែកដែរជួយឱ្យអ្នកថែទាំបន្តដឹងពីស្ថានភាពអ្នកជំងឺភ្លាមៗ ដោយមិនចាំបាច់ចំណាយពេលអានឯកសារលម្អិត ឬសាកសួរឡើងវិញដែលនាំឱ្យយឺតយ៉ាវ។

# ២.គោលបំណង

- អនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលយ៉ាងពេញទំហឹង
- ចែករំលែករបកគំហើញ និងបទពិសោធន៍នៃការប្រើឯកសារសម្រាប់ឆ្មប
- ចូលរួមកាត់បន្ថយអត្រាមរណៈភាព និង គ្រោះថ្នាក់ដល់មាតា និងទារក

# ៣.លទ្ធផលនៃការប្រើប្រាស់ សំណុំឯកសារថែទាំសម្រាប់ឆ្មបក្នុង NMCHC

01

ថ្ងៃទី01 ខែមេសា ឆ្នាំ2025

**ការដាក់ប្រើប្រាស់សាកល្បងនៅក្នុងមជ្ឈមណ្ឌលជាតិ**

ដើម្បីវាយតម្លៃប្រសិទ្ធភាពដំបូងមុននឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងមជ្ឈមណ្ឌល

02

ថ្ងៃទី16 ខែឧសភា ឆ្នាំ2025

**ការអនុម័តជាផ្លូវការ**

រដ្ឋមន្ត្រីក្រសួងសុខាភិបាល
**លោកសាស្ត្រាចារ្យ ឈាន រ៉ា**
បានអនុម័តដាក់ឱ្យ ប្រើជាផ្លូវការនៃសំណុំឯកសារថែទាំសម្រាក់ឆ្មបទូទាំងប្រទេស

03

ថ្ងៃទី01 ខែមិថុនា ឆ្នាំ2025

**ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ**

បន្ទាប់ពីអនុម័តដាក់អោយប្រើជាផ្លូវការ មជ្ឈមណ្ឌលជាតិបានរៀបចំរចនាសម្ព័ន្ធការងាររួចរាល់និងប្រើប្រាសជាផ្លូវការ

# ប្រព័ន្ធវាយតម្លៃសង្គ្រោះបន្ទាន់

## ចំណុចវាយតម្លៃ 8

1. ស្មារតី
2. ផ្លូវដង្ហើម និងការដកដង្ហើម
3. សញ្ញាស្តុក
4. សញ្ញាបម្រុង/ក្រឡាភ្លើង
5. គ្រុនក្តៅ
6. ការធ្លាក់ឈាម
7. ទំរង់បង្ហាញទារកមិនធម្មតា
8. ចង្វាក់បេះដូងទារក

**ឯកសារវាយតម្លៃសម្រាប់ឆ្មប**

**Assessment sheet for Midwives**

**ព័ត៌មានអ្នកជំងឺ**

ឈ្មោះ៖ ..........................................ថ្ងៃខែឆ្នាំកំណើត៖..............................អាយុ៖ ..........................ឆ្នាំ

លេខកូដចូលសម្រាកពេទ្យ៖...................................ផ្នែក..........................បន្ទប់..........................គ្រែ...........

| វាយតម្លៃករណីសង្គ្រោះបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ៖ | | |
|---|---|---|
| ១ | ស្មារតី៖ | ☐ វង្វេងវង្វាន់ ☐ សន្លប់ ☐ ប្រកាច់ |
| ២ | ផ្លូវដង្ហើម និងការដកដង្ហើម៖ | ☐ អត់ដង្ហើម ☐ ពិបាកដកដង្ហើម ☐ ខ្លីនិងញាប់ (> ៣០ដង/នាទី) |
| | | ☐ យឺត ☐ កំហាប់អុកស៊ីសែនក្នុងឈាម ($SpO_2$ < 94%)<br>☐ ពណ៌ស្វាយ(ជុំវិញបបូរមាត់) |
| ៣ | សញ្ញាស្តុក៖ | ☐ ជីពចរញាប់ (> ១០០ដង/នាទី) ☐ ស្បែកញើសស្អិត |
| | | ☐ សម្ពាធឈាមអតិបរមា(ស៊ីស្តូលីក)ចុះទាប(<៩០មមបារ៉ត) |
| ៤ | សញ្ញាបម្រុងក្រឡាភ្លើង/ក្រឡាភ្លើង | ☐ សម្ពាធឈាមអប្បបរមា(ឌីយ៉ាស្តូលីក) ≥ ១១០មមបារ៉ត ហើយប្រូតេអ៊ីនក្នុងទឹកនោម(+++) |
| | | ☐ សម្ពាធឈាមអប្បបរមា(ឌីយ៉ាស្តូលីក) ≥ ៩០មមបារ៉ត ហើយប្រូតេអ៊ីនក្នុងទឹកនោម(++) រួមនឹងសញ្ញាណាមួយមាន ឈឺក្បាលខ្លាំង ស្រវាំងភ្នែក ចុកចុងដង្ហើម |
| ៥ | គ្រុនក្តៅ៖ | ☐ > ៣៨⁰C |
| ៦ | ធ្លាក់ឈាម៖ | ☐ ធ្ងន់ធ្ងរ |
| ៧ | ការបង្ហាញទារកមិនធម្មតា៖ | ☐ ថ្ងាស ☐ មុខ ☐ ទទឹងពោះ ☐ បញ្ឆិតពោះ<br>☐ កូនទទឹងពោះធ្លាក់ដៃ ☐ កូនបញ្ច្រាស ☐ ដៃទូលក្បាល ☐ ធ្លាក់ទងសុកមកមុន |
| ៨ | ចង្វាក់បេះដូងទារក៖ | ☐ គ្មាន ☐ ខ្សោយ (<១១០ ឬ >១៦០ដង/នាទី) |
| ករណីមានតម្រូវការសង្គ្រោះជីវិតបន្ទាន់ក្រៅពីសម្ភព៖ | | |
| ☐ ត្រូវបញ្ជូនទៅផ្នែកពាក់ព័ន្ធ ☐ អញ្ជើញគ្រូពេទ្យជំនាញ/ឯកទេសផ្សេងទៀត ☐ បញ្ជូនទៅមន្ទីរពេទ្យដែលមានកម្រិតខ្ពស់ជាង | | |

# ប្រព័ន្ធវាយតម្លៃ និងការសម្រេចចិត្តសង្គ្រោះបន្ទាន់

Emergency Triage & Color-Coded Risk Classification

## ការបែងចែកកម្រិតគ្រោះថ្នាក់តាមពណ៌

ការប្រើប្រាស់ប្រព័ន្ធចំណាត់ថ្នាក់តាមរយៈពណ៌ គឺជាយុទ្ធសាស្ត្រគន្លឹះក្នុងការកំណត់អត្តសញ្ញាណអ្នកជំងឺដែលមានហានិភ័យខ្ពស់បានរហ័ស។ វិធីសាស្ត្រនេះជួយឱ្យបុគ្គលិកសុខាភិបាលធ្វើការសម្រេចចិត្តបានត្រឹមត្រូវក្នុងស្ថានភាពបន្ទាន់។

### ធម្មតា

ស្ថានភាពមាតាស្ថិតស្ថេរ តាមដានទៀងទាត់

### សញ្ញាប្រយ័ត្ន

ត្រូវការការយកចិត្តទុកដាក់ តាមដាន ត្រួតពិនិត្យលំអិត

### សញ្ញាគ្រោះថ្នាក់

ត្រូវការការអន្តរាគមន៍ភ្លាមៗ

# ប្រព័ន្ធវាយតម្លៃសម្រេចបន្ទាន់ (ត)

| វាយតម្លៃ | * ធម្មតា | **សញ្ញាប្រយ័ត្ន | ***សញ្ញាគ្រោះថ្នាក់ |
|---|---|---|---|
| ពត៌មានទូទៅ និងប្រវត្តិជំងឺ | | | |
| មន្ទីរពិសោធន៍ | | | |

| វាយតម្លៃ | | *ធម្មតា | **សញ្ញាប្រឈម | ***សញ្ញាគ្រោះថ្នាក់ |
|---|---|---|---|---|
| ពត៌មានទូទៅ និងប្រវត្តិជំងឺ | អាយុនៃគភ៌ពេលចូលសម្រាកពេទ្យ | ☐ សម្រាលគ្រប់ខែ | ☐ មិនដឹង (មិនច្បាស់លាស់) | ☐ សម្រាលមិនគ្រប់ខែ (< ៣៧សប្តាហ៍)<br>☐ សម្រាលលើសខែ (≥ ៤២សប្តាហ៍) |
| | អាយុស្ត្រី | ☐ ១៨-៣៤ឆ្នាំ | ☐ ក្មេងពេក (១៦-១៧ឆ្នាំ)<br>☐ ≥ ៣៥ឆ្នាំ កូនច្រើនដង | ☐ ក្មេងពេក (≤១៥ឆ្នាំ)<br>☐ > ៣៥ឆ្នាំ កូនដំបូង |
| | ចំនួនផ្ទៃពោះ | | | ☐ ≥ ៥ដង |
| | ចំនួនសម្រាល | ☐ ≤ ៣ដង | ☐ ៤ដង | ☐ ≥ ៥ដង |
| | ចំនួនរលូត ឬរំលូត | ☐ គ្មាន | ☐ រំលូត≥១ដង | |
| | ចំនួនកូនក្នុងផ្ទៃ | ☐ គភ៌កូន១ | | ☐ គភ៌កូនច្រើន |
| | កម្ពស់ស្ត្រី | ☐ > ១៥០សម | ☐ ១៤៥ -១៥០សម | ☐ <១៤៥សម |
| | ប្រវត្តិសម្រាលផ្ទៃពោះមុន | | ☐ សម្រាលដោយបូមជប់<br>☐ រហែកទ្វារមាសកម្រិត៣<br>☐ បើរីណេមានស្នាមថ្មេរ<br>មានផ្ទៃ ផុះសាច់/សិរមាន់<br>☐ សរសៃឈាមវ៉ែនឡើងប៉ោង<br>☐ កូនមិនគ្រប់លក្ខណៈ | ☐ បម្រុងក្រឡាភ្លើង/ក្រឡាភ្លើង<br>☐ ធ្លាប់ប្រកាច់<br>☐ ធ្លាប់ធ្លាក់ឈាមក្រោយសម្រាល<br>☐ ធ្លាប់សម្រាលដោយវះកាត់<br>☐ ធ្លាប់មានកូនកើតមកមានទំងន់ទាបធៀបនឹងអាយុគភ៌<br>☐ សម្រាលកូនមិនគ្រប់ខែ<br>☐ សម្រាលកូនគ្រប់ខែតែមិនគ្រប់គីឡូ<br>☐ កូនស្លាប់ក្នុងពោះ ឬកូនកើតស្លាប់ |
| | ប្រវត្តិជំងឺទូទៅ | ☐ គ្មាន | ☐ ធ្លាប់វះកាត់ផ្សេងៗ<br>☐ ធ្លាប់មានអាលែកហ្ស៊ី | ☐ មានជំងឺទឹកនោមផ្អែម ☐ មានជំងឺបេះដូង<br>☐ មានជំងឺផ្លូវដង្ហើម ☐ ធ្លាប់បញ្ចូលឈាម<br>☐ មានជំងឺលើសសម្ពាធឈាមរ៉ាំរ៉ៃ<br>☐ ធ្លាប់មានគ្រោះថ្នាក់ចរាចរណ៍ |
| មន្ទីរពិសោធន៍ | ស្ថានភាព<br>ផ្ទុកមេរោគអេដស៍/ស្វាយ<br>រលាកថ្លើមប្រភេទបេ | អវិជ្ជមាន<br>☐ អេដស៍<br>☐ ស្វាយ<br>☐ រលាកថ្លើមបេ | មិនធ្លាប់ធ្វើតេស្ត<br>☐ អេដស៍<br>☐ ស្វាយ<br>☐ មេរោគថ្លើមប្រភេទបេ | វិជ្ជមាន<br>☐ អេដស៍<br>☐ ស្វាយ<br>☐ រលាកថ្លើមប្រភេទបេ |
| | អេម៉ូគ្លូប៊ីន (ពិនិត្យភាពស្លេកស្លាំង) | ☐ > 11g/dl<br>ធម្មតា ឬមិនមានស្លេកស្លាំង | ☐ 7-11g/dl<br>ស្លេកស្លាំងមធ្យម ឬកម្រិតស្រាល | ☐ < 7g/dl<br>ស្លេកស្លាំងធ្ងន់ធ្ងរ |

| វាយតម្លៃ | * ធម្មតា | **សញ្ញាប្រយ័ត្ន | ***សញ្ញាគ្រោះថ្នាក់ |
|---|---|---|---|

# ពិនិត្យរាងកាយ

| ពិនិត្យរាងកាយ | វាយតម្លៃ | *ធម្មតា | **សញ្ញាប្រយ័ត្ន | ***សញ្ញាគ្រោះថ្នាក់ |
|---|---|---|---|---|
| | ស្ថានភាពស្ត្រី | | | |
| | ១ សម្ពាធឈាម | ☐ ស៊ីស្តូលិក <១៤០មមបារ៉ត និងឌីយ៉ាស្តូលិក <៩០មមបារ៉ត | ☐ សម្ពាធឈាមអប្បបរមា (ស៊ីស្តូលិក)≥១៤០មមបារ៉ត<br>☐ សម្ពាធឈាមអប្បបរមា (ឌីយ៉ាស្តូលិក)≥៩០មមបារ៉ត | ☐ សម្ពាធឈាមអប្បបរមា (ស៊ីស្តូលិក)≥១៦០មមបារ៉ត<br>☐ សម្ពាធឈាមអប្បបរមា (ឌីយ៉ាស្តូលិក)≥១១០ មមបារ៉ត |
| | ២ សញ្ញានៃការលើសសម្ពាធឈាម | ☐ មិនមានសញ្ញា | | ☐ ឈឺក្បាលខ្លាំង<br>☐ ស្រវាំងភ្នែក ឬឈឺនៅចុងដង្ហើម |
| | ៣ ជីពចរ | | ☐ ≥ ១១០/នាទី | |
| | ៤ កម្ដៅរាងកាយ | ☐ <៣៧.៥ºC | ☐ > ៣៧.៥ºC | ☐ > ៣៨ºC មានបែកស្រោមទឹកភ្លោះ<br>☐ ធ្លាក់សមានក្លិនស្អុយមានសញ្ញាបង្ករោគ |
| | ៥ ការពិនិត្យទឹកនោម | ☐ គ្មានប្រូតេអ៊ីន ឬ ប្រូតេអ៊ីនក្នុងទឹកនោម(+) | ☐ ប្រូតេអ៊ីនក្នុងទឹកនោម(++) | ☐ ប្រូតេអ៊ីនក្នុងទឹកនោម ≥ (+++) |
| | ៦ ធ្លាក់ឈាមតាមទ្វារមាស | ☐ ធ្លាក់រំអិលលាយឈាមតិចៗ | ☐ ធ្លាក់រំអិលលាយឈាមច្រើនជាងធម្មតា | ☐ ជោកសំឡីអនាម័យ ឬក្រណាត់ទ្រាប់ ក្នុងអំឡុង <៥នាទី |
| | ៧ ផ្នែកចិត្តសាស្ត្រ | | | |
| | អត្តចរិក៖ | ☐ ស្លូតបូត | ☐ ឆេវឆាវ | |
| | ការទំនាក់ទំនង៖ | ☐ ទំនាក់ទំនងល្អ | ☐ ឯកការ | |
| | ស្ថានភាពអារម្មណ៍៖ | | ☐ ស្ងប់ស្ងាត់ | ☐ ពុះកញ្ជ្រោល ☐ ធ្លាក់ទឹកចិត្ត |
| | ក្តីកង្វល់ | ☐ គ្មាន | ☐ មាន | |
| | សំណួររបស់ស្ត្រី | ☐ មាន | ☐ គ្មាន | |
| | បើមានសូមបំពេញ........................ | | | |
| | ៨ ផ្នែកសង្គម | | | |
| | - កម្រិតជីវភាព៖ ☐ បសស ☐ មូលនិធិសមធម៌ ☐ បង់ខ្លួនឯង ☐ ធានារ៉ាប់រង ☐ ផ្សេងៗ ....................<br>- ស្ថានភាពគ្រួសារ៖ ☐ នៅលីវ ☐ រៀបការ ☐ មេម៉ាយ<br>- ជំនួយពីសង្គម៖ ☐ ការប្រើប្រាស់ធនធានសហគមន៍ ☐ ការចូលរួមរបស់បុគ្គលិកសង្គមកិច្ច | | | |

| ពិនិត្យរាងកាយ | | | | |
|---|---|---|---|---|
| | ៩ ជំនឿ និងសាសនា | | | |
| | - សាសនា៖ ☐ ព្រះពុទ្ធ ☐ គ្រិស្ត ☐ អ៊ីស្លាម ☐ ផ្សេងៗ................<br>- ជំនួយខាងផ្លូវវិញ្ញាណ៖ ☐ អុជធូប ☐ អធិដ្ឋាន ☐ ថ្វាយបង្គំ ☐ ផ្សេងៗ................ | | | |
| | ១០ ចំណេះដឹងស្ត្រីអំពីការថែទាំសុខភាព និងរបបអាហារ៖ | | | |
| | - ដំណើរការមានផ្ទៃពោះ/ ការសម្រាល៖ ☐ មាន ☐ គ្មាន<br>- ការថែទាំពេលមានផ្ទៃពោះ៖ ☐ មាន ☐ គ្មាន<br>- ការថែទាំពេលសម្រាល៖ ☐ មាន ☐ គ្មាន<br>- ការថែទាំក្រោយសម្រាល៖ ☐ មាន ☐ គ្មាន<br>- របបអាហារ៖ ☐ របបអាហារទៀងទាត់ ☐ អាហារមានតុល្យភាព ☐ វីតាមីនមុនពេលសម្រាល ☐ អាហារបំប៉ន ☐ កង្វះជាតិទឹក<br>តម្រូវការអប់រំ៖........................ | | | |
| | ១១ លំហាត់ប្រាណ និងការសម្រាក/គេងពេលមានផ្ទៃពោះ៖ | | | |
| | - លំហាត់ប្រាណទៀងទាត់៖ ☐ មាន ☐ គ្មាន<br>- សម្រាកពេលថ្ងៃ៖ ☐ គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់<br>- គេង៖ ☐ គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់ | | | |
| | ស្ថានភាពទារកក្នុងផ្ទៃពោះ | | | |
| | ១ ចង្វាក់បេះដូងទារក | ☐ ១១០-១៦០/នាទី | ☐ ១០០<ចង្វាក់បេះដូង>១៦០ | ☐ គ្មានចង្វាក់បេះដូងទារក<br>☐ ≤១០០ដង/នាទី ☐ ≥១៨០ដង/នាទី |
| | ២ ទឹកភ្លោះ | ☐ ថ្លា | ☐ ទឹកភ្លោះលាយលាមករំព្រៃរ ហើយមិនមានក្លិនស្អុយ<br>☐ អត់ទឹកភ្លោះក្រោយបែកស្រោមទឹកភ្លោះ | ☐ ទឹកភ្លោះលាយឈាម<br>☐ ទឹកភ្លោះលាយលាមករំព្រៃខាប់(ទឹកភ្លោះពណ៌បៃតងចាស់ ឬខ្មៅ មានលាយលាមករំព្រៃដុំៗ)<br>☐ មានក្លិនស្អុយ |
| | ៣ សណ្ឋានទារក | ☐ បណ្ដោយស្បូន | | ☐ ទទឹងពោះ ☐ បញ្ឆិតពោះ |
| | ៤ ទម្រង់បង្ហាញទារក | ☐ កំពូលក្បាល | | ☐ បញ្ច្រាស ☐ ហុចស្មា<br>☐ ថ្ងាស ឬមុខ ☐ បង្ហាញដៃទូលក្បាល |
| | ៥ ការបង្ហាញរបស់ទារក | ☐ អុកស៊ីពុតនៅខាងមុខ | ☐ អុកស៊ីពុតនៅក្រោយ<br>☐ អុកស៊ីពុតនៅទទឹង | |

ការវាយតម្លៃមាត់ស្បូននៅពេលលូកពិនិត្យទ្វារមាស

| | ឈឺពោះពិតប្រាកដ | ឈឺពោះមិនពិតប្រាកដ |
|---|---|---|
| ប្រវែងមាត់ស្បូន | ≥ ៥០% (២សម) | < ២៥% (៤សម) |
| សភាពមាត់ស្បូន | ទន់ | រឹង |
| ទីតាំងមាត់ស្បូន | មុខ ឬកណ្តាល | ក្រោយ |
| ការបើកមាត់ស្បូន | ≥ ១សម | បិទ |
| កំណត់សម្គាល់៖ នៅពេលវាយតម្លៃឃើញថាមាត់ស្បូនស្ថិតនៅស្ថានភាពឈឺពោះពិតប្រាកដ រួមទាំងមានសញ្ញាកន្ត្រាក់នៃស្បូន ទៀតទាត់ និងមានរំអិលលាយឈាមតិចៗ ឆ្មបចាប់ផ្តើមបំពេញប៉ាតូក្រាហ្វ និងធ្វើការតាមដានបន្ត។ | | |

# ដំណាក់កាលតាមដានការសម្រាល និងការថែទាំក្រោយសម្រាល

## I ដំណាក់កាលទី 1

ចាប់ពីឈឺពោះពិតប្រាកដ
រហូតដល់មាត់ស្បូន
បើកបាន ១0cm

## II ដំណាក់កាលទី 2

ចាប់ពីមាត់ស្បូន ១0cm
រហូតដល់ទារកសម្រាលផុត

## III ដំណាក់កាលទី 3

ការទម្លាក់សុក
ការចាក់អុកស៊ីតូស៊ីន
ការគ្រប់គ្រងការធ្លាក់ឈាម

## IV ដំណាក់កាលទី 4

ការតាមដាន ២ ម៉ោង
ក្រោយសម្រាល
សញ្ញាជីវិតមាតា & ទារក

### ការវាយតម្លៃទារក - ពិន្ទុ Apgar

- ពណ៌សម្បុរ
- ចង្វាក់បេះដូង
- ទេផ្លិច
- កម្លាំងសាច់ដុំ
- ដង្ហើម

### ការតាមដានក្រោយសម្រាល - មាតា & ទារក

**មាតា:** • សម្ពាធឈាម • ជីពចរ • ការកន្ត្រាក់ស្បូន • ការធ្លាក់ឈាម • កម្តៅ ។ល។

**ទារក:** ដង្ហើម • កម្តៅ • ទម្ងន់ • ការបំបៅដោះ ។ល។

# ការតាមដានការសម្រាល និងការថែទាំក្រោយសម្រាល (ត)






# ការថែទាំតាមដានសុខភាពប្រចាំថ្ងៃ

## ម្តាយ

- ពិនិត្យកម្រិតអុកស៊ីសែន
- ការចុះនៃកំពូលស្បូន
- ស្នាមវះកាត់
- បញ្ហាសរសៃវ៉ែននៅជើង
- សម្ពាធឈាម • ជីពចរ • កម្តៅ
- តុល្យភាពសារធាតុរាវ (Intake/Output)
- ការបន្ទោរបង់ (ទឹកនោម/លាមក)



# ការថែទាំតាមដានសុខភាពប្រចាំថ្ងៃ

## ទារក

- ការពិនិត្យភ្នែក
- ការពិនិត្យមាត់
- ការពិនិត្យផ្ចិត
- ការពិនិត្យស្បែក
- ការឡើងឬចុះទម្ងន់
- ការដកដង្ហើម
- ការបំបៅដោះ (ទឹកដោះម្ដាយ)

ក្រសួងសុខាភិបាល

ឈ្មោះអ្នកជំងឺ.......................អាយុ........ ភេទ ........
លេខកូដ៖......................................................................
ផ្នែក..................បន្ទប់លេខ..........គ្រែលេខ.............

### សាលាកប័ត្រតាមដានទារកប្រចាំថ្ងៃ

| កាលបរិច្ឆេទ | ថ្ងៃទី០ | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ថ្ងៃទី៤ | ថ្ងៃទី៥ | ថ្ងៃទី៦ | ថ្ងៃទី៧ | ថ្ងៃទី៨ |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |
| ការពិនិត្យទារកទើបកើត | | | | | | | | | |
| ភ្នែក | | | | | | | | | |
| មាត់ | | | | | | | | | |
| ទងសុក | | | | | | | | | |
| ស្បែក | | | | | | | | | |
| ការបៅ | | | | | | | | | |
| ទឹកនោម | | | | | | | | | |
| លាមក | | | | | | | | | |
| ផ្សេងៗ | | | | | | | | | |
| គីឡូក្រាម/ក្រាម | | | | | | | | | |
| 4000 | | | | | | | | | |
| 3900 | | | | | | | | | |
| 3800 | | | | | | | | | |
| 3700 | | | | | | | | | |
| 3600 | | | | | | | | | |
| 3500 | | | | | | | | | |
| 3400 | | | | | | | | | |
| 3300 | | | | | | | | | |
| 3200 | | | | | | | | | |
| 3100 | | | | | | | | | |
| 3000 | | | | | | | | | |
| 2900 | | | | | | | | | |
| 2800 | | | | | | | | | |
| 2700 | | | | | | | | | |
| 2600 | | | | | | | | | |
| 2500 | | | | | | | | | |
| 2400 | | | | | | | | | |
| 2300 | | | | | | | | | |
| 2200 | | | | | | | | | |
| 2100 | | | | | | | | | |
| 2000 | | | | | | | | | |
| ទម្ងន់ទារក១០%នៃទម្ងន់ដើម | ..................................... | | | | | | | | |

កំណត់សម្គាល់៖ សូមជម្រាបគ្រូពេទ្យកុមារ ប្រសិនបើទារកចុះទម្ងន់១០%នៃទម្ងន់ដើម ឬទារកពុំឡើងទម្ងន់ពេលចេញពីមន្ទីរពេទ្យ

# របាយការណ៍ស្ថិតិ និងការវិភាគទិន្នន័យអ្នកជំងឺនៅក្នុង

# មជ្ឈមណ្ឌលជាតិគាំពារ មាតានិងទារក

National Maternal & Child Health Center

ចាប់ពីថ្ងៃទី01 ដល់ 31 ខែមីនា ឆ្នាំ2026



អ្នកជំងឺចូលសម្រាកសរុប

**1,283**

ការសម្រាលសរុប

**1,127**

# ទិដ្ឋភាពទូទៅ - ខែមីនា ២០២៦

| 1,283 | 1,127 | 156 |
| --- | --- | --- |
| ចំនួនអ្នកជំងឺសរុប | ករណីសម្រាល | សម្រាក+ត្រឡប់ទៅផ្ទះ |

របាយការណ៍នេះបង្ហាញពីទិន្នន័យស្ត្រីដែលបានមកសម្រាកព្យាបាល ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងករណីសម្រាល

# ការបែងចែកតាមកម្រិតហានិភ័យ (Triage)

| ពណ៌ក្រហម<br>***សញ្ញាគ្រោះថ្នាក់ | ពណ៌លឿង<br>**សញ្ញាប្រយ័ត្ន | ពណ៌បៃតង<br>* ធម្មតា |
|---|---|---|
| សរុប : 359 (28,0%) | សរុប : 486 (37,9%) | សរុប : 438 (34,1%) |
| • វះកាត់: ២៦៧ នាក់<br>• អន្តរាគមន៍: ៦ នាក់<br>• ធម្មជាតិ: ៧៨ នាក់<br>• ត្រឡប់ទៅផ្ទះ: ៨ នាក់ | • វះកាត់: ១៧៦ នាក់<br>• អន្តរាគមន៍: ៥៧ នាក់<br>• ធម្មជាតិ: ១៦៧ នាក់<br>• ត្រឡប់ទៅផ្ទះ: ៨៦ នាក់ | • វះកាត់: ៨៦ នាក់<br>• អន្តរាគមន៍: ១៦ នាក់<br>• ធម្មជាតិ: ២៧៤ នាក់<br>• ត្រឡប់ទៅផ្ទះ: ៦២ នាក់ |

# លទ្ធផលក្រោយចូលសម្រាកពេទ្យ (គិតជាភាគរយ)




| | វះកាត់: | អន្តរាគមន៍: | ធម្មជាតិ: | ត្រឡប់ទៅផ្ទះ: | វះកាត់: | អន្តរាគមន៍: | ធម្មជាតិ: | ត្រឡប់ទៅផ្ទះ: | វះកាត់: | អន្តរាគមន៍: | ធម្មជាតិ: | ត្រឡប់ទៅផ្ទះ: |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ភាគរយ | 74.4 | 1.7 | 21.7 | 2.2 | 36.2 | 11.7 | 34.4 | 17.7 | 19.6 | 3.7 | 62.6 | 14.2 |

ក្រហម=359 លឿង=486 បៃតង=438

# លទ្ធផលនៃការសម្រាល




| | ក្រហម | លឿង | បៃតង |
|---|---|---|---|
| វះកាត់ | 267 | 176 | 86 |
| អន្តរាគមន៍ | 6 | 57 | 16 |
| ធម្មជាតិ | 78 | 167 | 274 |

វះកាត់ អន្តរាគមន៍ ធម្មជាតិ



# ការបែងចែកពណ៌ ចំពោះក្រុមពណ៌បៃតង

## ការបែងចែកអ្នកជំងឺទៅតាមពណ៌ក្នុងពេលថៃទាំ ចំពោះក្រុមពណ៌បៃតងពេលចូលសម្រាកពេទ្យ សរុប 438




អ្នកជំងឺក្រុមក្រហម 92 នាក់ (21.0%)

អ្នកជំងឺក្រុមលឿង 21 នាក់ (4.8%)

អ្នកជំងឺក្រុមបៃតង 325 នាក់ (74.2%)

# ៤.លទ្ធផលស្ទង់មតិឆ្លុះ

## ការប្រើប្រាស់ឯកសារថែទាំកូដពណ៌សម្រាប់ស្ត្រីមានផ្ទៃពោះចូលសម្រាកពេទ្យ

ចំនួនសរុប៖ ៧០ រូប ផ្នែកសម្ភព ។ ថ្ងៃទី៣០ មិថុនា ២០២៦
ដោយប្រើ QR

# 1 តើការប្រើឯកសារថៃទាំសម្រាប់ឆ្មបនេះមានសារសំខាន់ដែរឬទេ?




## ១០០%

ឆ្មបទាំង ៧០ រូប (១០០%) ឆ្លើយថាឯកសារនេះមានសារសំខាន់

## ហេតុផលសំខាន់ៗ

- ជួយកត់ត្រា និងរក្សាទុកព័ត៌មាន/ប្រវត្តិអ្នកជំងឺបានត្រឹមត្រូវ
- ងាយស្រួលតាមដានស្ថានភាព និងរកឃើញសញ្ញាគ្រោះថ្នាក់ទាន់ពេលវេលា
- ជាភស្តុតាងផ្នែកច្បាប់ ការពារវិជ្ជាជីវៈឆ្មប
- សម្រួលការផ្ទេរព័ត៌មានរវាងវេនការងារ
- ជួយសម្រេចចិត្តព្យាបាល និងសង្គ្រោះបានទាន់ពេលវេលា

## 2 តើគួរប្រើឯកសារនេះ គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់ដែរឬទេ?




### ១០០%

ឆ្មបទាំង ៧០ រូប (១០០%) យល់ថាគួរប្រើឯកសារនេះជាមួយស្ត្រីមានផ្ទៃពោះទាំងអស់ដែលចូលសម្រាកព្យាបាល។

### ហេតុផលសំខាន់ៗ

- ស្ត្រីមានផ្ទៃពោះនីមួយៗមានប្រវត្តិ/ស្ថានភាពខុសគ្នា ត្រូវការតាមដានផ្ទាល់ខ្លួន
- ជួយកំណត់ភាពប្រឈម និងធានាបន្តការថែទាំគ្រប់ករណី
- ជាឯកសារយោង សម្រាប់ការវាយតម្លៃ និងផែនការថែទាំបន្ត
- សម្រួលការផ្ទេរព័ត៌មាន និងធានាស្តង់ដារសេវាដូចគ្នា
- ងាយស្រួលក្នុងការពិនិត្យ និងតាមដានអ្នកជំងឺ

## 3 តើការបែងចែកពណ៌ទៅតាមស្ថានភាពរបស់ជំងឺ មានសារសំខាន់ដែរឬទេ?




**១០០%**

ឆ្មបទាំង ៧០ រូប (១០០%) ឆ្លើយថាការបែងចែកពណ៌តាមស្ថានភាពជំងឺ មានសារសំខាន់ខ្ពស់។

### ហេតុផលសំខាន់ៗ

- ជួយកំណត់កម្រិតហានិភ័យ និងអាទិភាពនៃការសង្គ្រោះបានលឿន
- ងាយស្រួលវាយតម្លៃ និងសម្គាល់ស្ថានភាពស្រាល/ធ្ងន់
- ជួយគ្រូពេទ្យនិងឆ្មបសម្រេចចិត្តព្យាបាលបានលឿន
- ធ្វើឱ្យអ្នកជំងឺដែលមានស្ថានភាពធ្ងន់ទទួលការព្យាបាលទាន់ពេលវេលា

## 4 តើផ្តល់សេវាដូចគ្នាដល់ស្ត្រីទាំងអស់ ឬផ្តល់អាទិភាពទៅតាមកូដពណ៌?




■ ផ្តល់អាទិភាពតាមកូដពណ៌ (៦៧%)

■ ថៃទាំស្មើគ្នាទាំងអស់ (៣៣%)

### ៤៧/៧០ (៦៧%)

យល់ថាគួរផ្តល់អាទិភាពជួយសង្គ្រោះមុនចំពោះស្ត្រីដែលមានកូដពណ៌បង្ហាញហានិភ័យខ្ពស់ (ដូចជាកូដក្រហម)

### ២៣/៧០ (៣៣%)

យល់ថាស្ត្រីទាំងអស់គួរទទួលការយកចិត្តទុកដាក់ និងសេវាថៃទាំស្មើគ្នា ដោយមិនប្រកាន់តាមកូដពណ៌

*សំគាល់៖ ចម្លើយភាគច្រើនពន្យល់ថា ២ គំនិតនេះមិនផ្ទុយគ្នាទេ — ថៃទាំគ្រប់ស្ត្រីស្មើគ្នា ប៉ុន្តែផ្តល់អាទិភាពជួយករណីមានហានិភ័យខ្ពស់មុន។*

# 4 ហេតុអ្វី? — ថៃទាំស្មើគ្នា ឬ ផ្តល់អាទិភាពតាមកូដពណ៌?

## ផ្អែកលើកូដពណ៌ (៦៧%)

- កូដពណ៌បង្ហាញកម្រិតគ្រោះថ្នាក់ ត្រូវផ្តល់អាទិភាពជួយករណីធ្ងន់មុន
- ជួយសម្រេចចិត្តលឿន និងគ្រប់គ្រងហានិភ័យបានប្រសិទ្ធភាព
- ស្ថានភាពស្ត្រីម្នាក់ៗខុសគ្នា ត្រូវការថៃទាំតាមកម្រិតខុសគ្នា
- ជួយកំណត់ថាករណីណាត្រូវសង្គ្រោះបន្ទាន់មុនគេ

## មិនផ្អែកលើកូដពណ៌ (៣៣%)

- ស្ត្រីទាំងអស់មានសិទ្ធិទទួលការថៃទាំ/យកចិត្តទុកដាក់ស្មើគ្នា
- មិនអាចប៉ាន់ស្មានស្ថានភាពគ្រោះថ្នាក់បានតែម្តង ព្រោះអាចប្រែប្រួល
- ស្ត្រីមានផ្ទៃពោះទាំងអស់មិនមែនស្ថានភាពធម្មតាទាំងអស់គួរប្រុងប្រយ័ត្នស្មើគ្នា
- (ខ្លះក្នុងក្រុមនេះនៅតែសរសេរថា ក្នុងករណីបន្ទាន់ត្រូវផ្អែកលើកូដពណ៌ជាអាទិភាព)

*ចំណាំ៖ ចម្លើយមួយចំនួនក្នុងក្រុម "មិនផ្អែកលើកូដពណ៌" នៅតែទទួលស្គាល់ថាករណីបន្ទាន់ត្រូវការអាទិភាព បង្ហាញថាទស្សនៈទាំងពីរមិនផ្ទុយគ្នាទាំងស្រុងទេ។*

# 5 តើកូដពណ៌អាចប្រែប្រួលបានទេ ក្នុងអំឡុងពេលថៃទាំ?




## ១០០%

ឆ្មបទាំង ៧០ រូប (១០០%) យល់ថាកូដពណ៌អាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងរបស់ស្ត្រី។

## ហេតុផលសំខាន់ៗ

- ស្ថានភាពម្តាយ និងទារកអាចផ្លាស់ប្តូរគ្រប់ពេលវេលា (ធម្មតា→ធ្ងន់ ឬ ធ្ងន់→ធូរស្រាល)
- ត្រូវវាយតម្លៃឡើងវិញជាប្រចាំតាមការវិវត្តន៍ជាក់ស្តែង
- ការព្យាបាល/ការតាមដានត្រឹមត្រូវអាចធ្វើឱ្យស្ថានភាពប្រសើរឡើង
- ស្ថានភាពជំងឺមិនអាចប៉ាន់ស្មានជាមុនបានទាំងស្រុង

# ៥.សេចក្តីសន្និដ្ឋាន

### ការយល់ដឹងអំពីការកើនឡើងហានិភ័យនៃ 'បៃតង'

អ្នកជំងឺក្រុម 'បៃតង' អាចប្រែប្រួលទៅ 'លឿង' ឬ 'ក្រហម'
ដូចនេះត្រូវថែទាំប្រុងប្រយ័ត្ន
ដូច្នេះការដោះស្រាយបញ្ហាត្រឹមត្រូវគឺការចាំបាច់ណាស់

### តក្កវិជ្ជានៃការតាមដានបន្ទាន់

អ្នកជំងឺក្នុងក្រុម 'លឿង' ត្រូវបានតាមដានជាប់ជានិច្ច ដើម្បីរកសញ្ញាគ្រោះថ្នាក់ ហើយអន្តរាគមន៍បន្ទាន់ ដើម្បីការពារគ្រោះថ្នាក់

### បម្រែបម្រួលនៃកូដពណ៌ 'ក្រហម'

អ្នកជំងឺដែលចាត់ថ្នាក់ 'ក្រហម' អាចត្រឡប់ទៅ 'លឿង' ឬ 'បៃតង' វិញ
ក្រោយការថែទាំព្យាបាលជោគជ័យ ដែលបញ្ជាក់ពីប្រសិទ្ធភាពខ្ពស់
ការថែទាំព្យាបាលជោគជ័យ

### ប្រសិទ្ធភាព

ប្រព័ន្ធចាត់ចែងតាមពណ៌គឺចាំបាច់សម្រាប់ការព្យាបាលទាន់ពេល
ការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវ និងការការពារផ្នែកបង្ការ។

# ៦.អនុសាសន៍

- ការប្រើប្រាស់ប្រព័ន្ធចំណាត់ថ្នាក់ (Triage) ជួយអ្នកថែទាំធ្វើការសម្រេចចិត្តបានរហ័ស និងច្បាស់លាស់
- ការតាមដានតាមដំណាក់កាលអនុញ្ញាតឱ្យមានការប្តូរយុទ្ធសាស្រ្តអន្តរាគមន៍បន្ទាន់ភ្លាមៗ
- គ្រប់ចំណាត់ថ្នាក់នៃពណ៌ និងមានការប្រែប្រួលក្នុងអំឡុងពេលថែទាំព្យាបាល
- គ្រប់ស្រ្តីទាំងអស់ដែលចូលសម្រាកពេទ្យត្រូវតែប្រើប្រាស់ឯកសារនេះ ទោះស្ថានភាពធម្មតាក៏ដោយ
- ការគ្រប់គ្រងទិន្នន័យអ្នកជំងឺ និងប្រព័ន្ធថែទាំតាមស្តង់ដារ បង្កើតឱ្យមានការថែទាំគ្រប់ជ្រុងជ្រោយ

# សូមអរគុណ